HONEYCOMB 4/1 (January 2003): 75–85



# Do Justice, Love Mercy

## Combating tourism-based sexual exploitation of children

*Laurence GRAY*

### Introduction

*Lee is a fifteen-year-old girl lured by her aunt into prostitution. She was sold to a fifty-year-old American man for $400 for four days. After that she was forced to go with a twenty-five-year-old Japanese man for $50. Then the pimp brought her to sleep with a Chinese man far $30. Finally she slept with a forty-year-old Frenchman. The Frenchman slept with her for a month at his rented house. After that she came to stay in an entertainment establishment again. Two days later she was freed through a police raid and sent to an organization.*

Physically she was free, but her mind and spirit were still bound by her experience. In all probability true freedom will take much time and support. Linking children with opportunities to regain dignity is a ministry in itself. Challenging the principalities and powers that allow this type of exploitation to exist is the focus of this paper.

The Bible contains many examples of setting captives free. We need today to work toward this aim, while all the time realizing our limitation as broken people who are often captives ourselves. Galatians 5:1 states that Christ has set us free, and instructs us not to allow ourselves to become slaves again. To be a captive to anything

results in reduced potential. Some limitations, such as addiction, can be mitigated by a personal change of will or lifestyle. Others, such as poverty, are externally imposed and less easily remedied by the captive. God challenges us to fulfill our potential.

While it is possible to reflect dignity in adversity, captivity is not God's purpose for humanity. Nevertheless we see children in debt bondage and physical captivity through forced prostitution. Traffickers prey on children in villages, at markets, and on the street. Justice is often slow to act, as systems representing the poor never seem to catch up to the need. God tells us that there is a deceiver, a force working to diminish and destroy life. He appears as a snake in Genesis to tempt and distort. As we work to combat poverty and exploitation, and bring God's presence more fully into the brokenness of the world, we encounter this force of evil. As we work with others in this enterprise we must use the armor God gives to us, since our strength and will alone are not enough.

History provides examples of God's people bringing about change through striving for a different vision. Prophets have challenged the actions of ruling authorities. Leaders are called to account for their faithfulness and their care for the poor. Political success was not recognized if the most vulnerable had no voice in their favor. When the poor were not cared for, and laws absent or misused, God clearly called through the prophets for justice to be restored. The story of Jonah is but one example where a reluctant prophet was given an unpalatable message to tell the city of Nineveh that it needed to change its ways or be destroyed. Certainly Cambodia needs advocates who in the prophetic tradition speak for the defense of others—in this case for children who are exploited for pleasure and profit as tourism grows.

Speaking out can be effective, but if not planned wisely can cause further problems. We may be tempted to focus not so much on our message but on ourselves as messengers to gain credibility, respect, and praise. Jesus was tempted by the devil to perform miracles in the wilderness. He answered that people must not tempt the Lord their God. In order to balance opportunity and risk we need good council and prayer.

We are obligated to pray against exploitation. Joint prayer is an exercise in calling into being by faith an improved set of circumstances—"praying in the kingdom." Change does not always occur immediately before our eyes. The ending of slavery took hundreds of years, but it happened. More recently many people prayed for the ending of apartheid and for justice to come to South Africa. Many can petition governments or international bodies. This is needed especially when working on behalf of the poorest of the poor who have no voice of their own. Christians should be part of this process. Those who hold the Christian worldview are impelled to oppose oppression and injustice on both the spiritual and the political and social levels.

Christians believe that God has made all people in his image. Thus all have inherent dignity and the opportunity to know God. Sin is a barrier to this relationship, which was bridged by the death of Jesus who willingly gave himself for our sake. While Jesus' gift of reconciliation has given a new opportunity to relate with God, we are vulnerable to the influence opposing powers that seek to destroy and debase God's creation. Although we are often weak, we can be strengthened through God's love, and so exercise moral choice and oppose injustice practiced against others. Through our relationship with God our eyes will see and ears hear these things more keenly.

We also have promises from God on which we need to act. "Where two or three are gathered I am there." "Ask and it shall be given, seek and you will find." We need to own these promises, raise our voices to God in prayer, and act locally to the extent we can. As we do so God may call us to further action. A challenge to all is to listen for God's voice in a given situation. We may be called to be led rather than to lead, to change rather than control. This was the call to Peter—to allow himself to be led even to places to which he did not want to go. Prayer with others in humility and seeking God's grace in situations that cry out for intervention is something Christians can do through a personal relationship with their creator. A child being used as a tourism commodity traded for profit and pleasure is one such situation.

## Tourism

Cambodia attracted 270,000 visitors in 1999, a number predicted to triple in four years. Cambodia has much to offer with its proud heritage and famous Angkor temples. Recent history also attracts visitors to see this land that has emerged from the shadow of Year Zero. It is a new frontier with more excitement and mystery than those neighboring countries that have been on the tourist trail for decades.

Tourism also provides easy access to vulnerable children through the power and economic disparities fundamental to the "cheap third-world holiday—sun, surf and sex." This other side of Cambodia is promoted through word of mouth, Internet chat rooms, and sometimes publications. Thailand and the Philippines, wishing to mute their reputations as popular destinations for sex tourists, have taken legal moves to protect children. As these countries become more restricted, attention will turn elsewhere. Sex tourists are attracted by impoverished conditions that promote low cost of prostitution, wide availability, and perceived impunity from prosecution. Recent prosecutions and the jailing of an English schoolteacher have served notice that impunity is not assured. However in recent years Cambodia has been increasingly linked to child prostitution, and risks this reputation overshadowing the publicly promoted cultural heritage of the country as its principle association.

## The Effects of Sexual Violence on Children

Sexual violence can devastate young lives, as shown by this story of a sixteen-year-old girl. World Vision worked with her from 1999–2000.

*At age thirteen Sokha allowed herself to be sold for $600 to a foreigner to help her family pay for medical treatment. After that she practiced prostitution for two years until she became sick. When that happened, clients would not take her and she was thrown out on the street. We worked with her for over a year while she battled HIV. Sokha died at age sixteen, weighing less than 20 kilograms, with no family present. She touched others with her dignity in the*

*face of death, and through her a church became involved in visiting women at the Russian Hospital to bring support and the Good News.*

The story shows the powerlessness of the victim, abuse of power by the offenders, humiliation, physical assault, and isolation in suffering. World Vision partnered with Physicians for Human Rights in 1996 to write a report on the psychosocial effects of sexual exploitation. This study identified the following effects on children:

***Trauma.*** Sexual trauma is the violation of the most intimate and personal aspects of the self. One's own body becomes the setting in which the atrocities are perpetrated. For the young women living in the brothel the sexual violations take place inside the tiny cubical that is their only private living space. There is no safe haven for them.

***Shame.*** A powerful psychological reaction linked to the sexual nature of the trauma. Personal value falls sometimes to the point of seeing no other option because they are worthless.

***Betrayal of Trust.*** Approximately half the young women are sold to brothels by people that they know. This betrayal has long-lasting effects, and relationships develop slowly with children in recovery. Information is precious and sharing in it is earned.

***Layers of Truth.*** The inaccuracy of personal stories suggests coping mechanisms that the girls may have used. Some girls constantly need to reinvent themselves, as they are given a new name and history every week by brothel owners who want to control them and prevent the detection of a missing girl.

***Self-blame.*** Many girls blame their fate on themselves, assuming an exaggerated sense of their part in the events that led to their present circumstances.

***Disruption in Normal Development.*** Young women are forced into a role that separates them from the community. They are not able to participate in many informal socialization activities that would prepare them for future roles as income earner, wife, and mother.

***Separation from Family.*** Important relationships suffer. Many young women grieve loss of contact, particularly with siblings.

***Grief and Depression.*** A sense of hopelessness develops at the loss of freedoms, relationships, and innocence.

***Fear.*** Beatings and punishment from brothel owners are common. Young women are also fearful of contracting AIDS; however, they cannot refuse clients.

***Captivity.*** Young women have endured captivity for weeks, months, and sometimes years. Initially they may fight the brothel owner's demands that they service clients. This results in their being locked in a room for a week, or being beaten until they yield. They lose any sense of control over their own fate.

***Being a Good Daughter.*** In the Cambodian context this is a crucial factor. Many young women see themselves as being able to help their family survive through their prostitution. This gives context and meaning for their personal sacrifice.

These effects serve as a background for those who aid the recovery of survivors.

## Contributing Factors

World Vision undertook a joint study with the International Office of Migration in 1996 to understand the pattern of trafficking from Cambodia to Thailand. We found the following factors increase the risk to girls of being sold or trafficked:

*Poverty*
*Lack of education*
*Involvement of relatives*
*Ease of deception by traffickers (in situations where people do not know about traffickers, or are too trusting)*
*Lack of border control*
*Lack of vocational options*
*Community resignation to the existence of prostitution*

These factors are not exceptional in many countries. World Vision works in different ways with a variety of actors in the best interests of children.

## What Can Be Done Against This Background?

Freedom from exploitation is upheld through such international instruments as the Convention on the Rights of the Child and the Universal Declaration on Human Rights. Countries where the rule of law is strong have mechanisms to address crimes of exploitation. These include not only the legal system but also medical and human services. Public debate enables the public to express its views; helps hold the police, judiciary, and government accountable; and encourages debate on the need for change.

World Vision Cambodia as a child-focused Christ-centered agency places advocacy as a core activity in working with the poor, seeking justice and promoting transformation. It both uses its own voice to speak up on issues adversely affecting children, and helps the poor and marginalized to speak for themselves.

## Child Sexual Exploitation and Tourism Research Project

Sexual exploitation clearly violates the rights of children. World Vision undertakes projects that work with child victims. World Vision is therefore witness to the resulting damage done to the children—physical (sexually transmitted diseases), psychological, and social (stigmatism by family and society). These in turn lead to unemployment, isolation, sickness, and even death.

As a result, World Vision initiated an investigation of the link between the tourist industry and sexual exploitation of children in Cambodia. The research was conducted jointly by universities, NGOs, and government ministries (including the Ministry of Tourism). The investigation was structured along the following lines:

**Aim:** To reduce the incidence of child sexual exploitation in Cambodia, and to promote mechanisms to protect children from sexual exploitation through tourism.

**Objectives:**

- To raise awareness among Cambodian government ministries of the nature of the problem and how it can be tackled
- To raise awareness among children and their families of the nature and occurrence of the practice

- To reveal the need for cooperation between all sectors of the Cambodian government and civil society to work toward ending this practice.

**Activities:**

- Research project organized by World Vision Cambodia, in partnership with the government of Cambodia, the Cambodian National Council for Children, and the Ministry of Social Affairs, Labor, and Vocational Training.
- Publication of the report "Child's Work, Adult's Play: Report of Research on Child Sex Tourism in Cambodia." This report was distributed among various government ministries in Cambodia, as well as embassies, industry, and NGOS.

**Participants:**

Interviewees in Phnom Penh, Seam Riep, and Sihanoukville:

68 children (average age 15)
26 motorbike taxi drivers
32 government staff of Ministry of Tourism
14 government staff of Ministry of Social Affairs, Women's Affairs, provincial police departments
5 NGO staff
32 tourist facility, e.g., hotel guest house staff
20 general public

## Who is Involved in Child Sexual Exploitation?

The Ministry of Tourism says that 65% of tourists to Cambodia in the year 2000 were men. Research conducted with the Ministry of Tourism and The Cambodian National Children's Council in three main tourist locations revealed the following information from children themselves.

88% of children had been involved in providing sexual services for tourists. Information also came from twenty members of the general public who live close to entertainment establishments. They estimated that 42% of the girls were taken away from the facility by clients, 47% were left alone, and 9% were taken by pimps. It was estimated that 60% of the children who had contact with tourists were 14 to 18 years old, and 40% were 18 to 22 years old.

Twenty-two travel agents and tour operators in the three locations estimated that the main groupings of tourists were: those visiting for cultural tourism 32%; for business 25%; for official visits 20%; for sex tourism 22%.

According to the interviewees, the foreigners that contacted children for sexual intercourse were 45% Chinese, 22% French, 18% American, 4% Australian, and 36% unknown Westerners.

Among the twenty-eight Ministry of Tourism officers interviewed, 78% said that they saw children going with male foreigners. The interviewees identified the major groups of foreigners that the children went with as follows: 18% American, 18% Japanese, 14% Chinese, 9% French, and 32% European white-skinned men.

The impact to date of the study has been:

- Increased Government response in training, regulation, and monitoring of tour guides.
- Formulation of Government regulations for tour guides and commitment to regulate tourist services.
- Increased publicity of the issue locally, regionally, and internationally; i.e., media coverage in Khmer language press and CNN.
- A workshop planned with government, NGOs, and business on the tourism industry's role in combating sexual exploitation of children.
- Commitment from some tour operators to be partners with the Government and NGOs in promoting child-safe tourism.
- The Ministry of Tourism presents the study at the United Nations Economic and Social Commission for Asia and the Pacific regional inter-governmental conference on prevention of sexual exploitation of children linked to tourism.
- Continued cooperation with the Royal Government of Cambodia in the implementation action of their five-year plan to combat the sexual exploitation of children.
- The research has been used by the Asia Development Bank in forming its poverty alleviation strategy.

- The British embassy has funded World Vision to work with the Ministry of Tourism for two years to strengthen its training of tour guides and monitor this issue.

Responses from the Government as a result of the July 2000 study and the subsequent workshop have included:

- Convening of a further planning workshop with government, NGOs, and business on the tourism industry's role in combating sexual exploitation of children
- Commitment from several tour operators to partner with the government and NGOs in promoting child-safe tourism
- Increased links with industry and NGOs
- A Ministry of Tourism presentation of the July 2000 study at a regional inter-governmental conference on prevention of sexual exploitation of children linked to tourism
- Inclusion of study findings and key recommendations in the Royal Government of Cambodia Report to the Second World Congress against Commercial Sexual Exploitation of Children in Yokohama, December 2001.
- Continued cooperation by the Ministry of Tourism and NGOs with the Royal Government of Cambodia in the implementation of the five-year plan to combat the sexual exploitation of children
- Discussions with tour associations and businesses on self-regulation measures to enhance child protection.
- At the request of the Ministry of Tourism, the Asian Development Bank has included building government and tourism industry capacity to respond to commercially sexually exploited children as part of its assistance to the Cambodian government's Socio-economic Development Plan.

## Conclusion

Sexual violence directed at children is unacceptable. It requires action at many levels. Tourism is growing; it involves all countries; visitors include both domestic and foreign visitors. Industry standards are clearly needed. Prosecution is required, regardless of

the nationality of the offender. The world's governments, with the support of United Nations agencies and international organizations, have the responsibility to ensure that children are protected from such crimes. Developing countries need support through bilateral and multilateral initiatives to respond to these issues as part of their efforts to build civil societies. Further, the tourist sector has the obligation to move away from practices that allow the exploitation of children and promote child safety. Initiatives must also involve child participation in communities to promote a safer world for children. Community leaders need to be rallied so that it is no longer acceptable for a girl to be traded, or that a rapist pay only financially for his actions.

Failure to act will mean that we fail children like Sokha. We leave them only few options and a short, painful life. Christians know that this is not right, and through God's grace believe things can improve. We need to be challenged by these circumstances and not indifferent to them. To take action will build opportunity for children. Those with influence, economic power, and the privilege of choice can greatly influence the lives of children in poor areas near borders and tourist destinations. Our actions must reflect the seriousness of this task.

សំណាំទឹកឃ្មុំ ៤/១ (មករា ២០០៣)៖ ៨៦-១០៥



# ផ្តល់យុត្តិធម៌ សេចក្តីស្រឡាញ់ និង សេចក្តីមេត្តាករុណា

## ការប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ដែលមានមូលដ្ឋានលើការកេងប្រវញ្ចន៍ផ្លូវភេទរបស់កុមារ

*ល័រេន វេគ្រ*

## សេចក្តីផ្តើម

លី គឺជាកុមារីអាយុ ១៥ឆ្នាំ ត្រូវម្តាយមីងរបស់ខ្លួនល្បួងលោមបោកឲ្យទៅក្នុងរបរពេស្យាចារ ។ នាងត្រូវបានគេលក់ទៅឲ្យបុរសជនជាតិអាមេរិកាំងម្នាក់ អាយុ៥០ឆ្នាំ ក្នុងតម្លៃ៤០០ដុល្លារអាមេរិកសំរាប់៤ថ្ងៃ ។ បន្ទាប់ពីនោះមក នាងត្រូវបានបង្ខំឲ្យទៅជាមួយបុរសជនជាតិជប៉ុនម្នាក់ទៀតអាយុ ២៥ឆ្នាំ ក្នុងតំលៃ៥០ដុល្លារអាមេរិក ។ បន្ទាប់មកទៀតមេបនបាននាំនាងទៅដេកជាមួយបុរសចិនម្នាក់ក្នុងតម្លៃ ៣០ដុល្លារ អាមេរិក ។ ទីបំផុតនាងដេកជាមួយបុរសអាយុ៤០ឆ្នាំជនជាតិបារាំងម្នាក់ទៀត ។ ជនជាតិបារាំងម្នាក់នេះ បានដេកជាមួយនាងអស់រយៈពេលមួយខែនៅឯផ្ទះជួលរបស់គេ ។ បន្ទាប់មក នាងត្រូលប់មកស្នាក់នៅកន្លែងទទួលភ្ញៀវរបស់នាងម្តងទៀត ។ បន្ទាប់ពី២ថ្ងៃក្រោយមក នាងបានមានសេរីភាពដោយក្រុមប៉ូលីសកំចាត់ពេស្យាចារ ហើយបានបញ្ជូននាងទៅឯអង្គការមួយ ។

ចំពោះរូបរាងកាយនាងមានសេរីភាពមែន ប៉ុន្តែគំនិត និងវិញ្ញាណរបស់នាងនៅតែជាប់ចំណងដោយបទពិសោធន៍របស់នាង ។ ប្រហែលជានៅក្នុងគ្រប់ទាំងសេរីភាពនៃសេចក្តីពិតទាំងអស់ត្រូវតែមានការជួយផ្គត់ផ្គង់ និងចំណាយពេលច្រើនថែមទៀត ។ ការភ្ជាប់ក្មេងជាមួយនឹងឱកាសដើម្បីទទួលនូវសេចក្តីថ្លៃថ្នូរឡើងវិញ នេះគឺជាព័ន្ធកិច្ចមួយពិតប្រាកដហើយ ។ ការទប់ស្កាត់នូវវិញ្ញាណ និងអំណាចដែលអនុញ្ញាតឲ្យមាននូវប្រភេទនៃទោហនកម្មនេះ គឺជាការផ្តោតចិត្តទុកដាក់របស់មេរៀននេះ ។

មានគំរូជាច្រើននៅក្នុងព្រះគម្ពីរនៃការរំដោះពួកឈ្លើយឲ្យមានសេរីភាព ។ សព្វថ្ងៃនេះយើងត្រូវតែធ្វើឆ្ពោះទៅចំពោះគោលដៅនេះក្នុងខណៈពេលដែលទទួលស្គាល់ពីភាពមានព្រំដែនរបស់ខ្លួន ក្នុងគ្រប់ពេលទាំងអស់ទុកដូចមនុស្សដែលមានការឈឺចាប់ ដែលតែងតែដាក់ខ្លួនឯងជាឈ្លើយ ។ កាឡាទី ៥:១ បាននិយាយថា ព្រះគ្រីស្តបានរំដោះយើងឲ្យមានសេរីភាពហើយ ហើយបានបង្រៀនយើងមិនឲ្យក្លាយទៅជាទាសករម្តងទៀតទេ ។ ការធ្លាក់ខ្លួនទៅជាឈ្លើយនៃរបស់អ្វីមួយហុចលទ្ធផលជាការកាត់បន្ថយសក្តានុពល ។ ភាពមានព្រំដែនខ្លះ ដូចជាការញៀនថ្នាំអាចបន្ធូរបាន ដោយការផ្លាស់ប្រែផ្លាល់ខ្លួននៃបំណងចិត្ត និងជីវិតប្រចាំថ្ងៃ ។ អ្វីៗផ្សេងៗទៀត ដូចជា ភាពក្រីក្រ គឺជាសភាពគ្របដណ្តប់ខាង ក្រៅ ហើយមានភាពមិនសូវជាងាយស្រួលឲ្យឈ្លើយព្យាបាលនោះ ឡើយ ។ ព្រះជាម្ចាស់ជំរុញឲ្យយើងបំពេញសក្តានុពល របស់យើង ។

ក្នុងខណៈពេលដែលអាចឆ្លុះបញ្ចាំងសេចក្តីថ្លៃថ្នូរបាន នៅក្នុងការលំបាក ព្រះជាម្ចាស់គ្មានបំណងចង់ឲ្យមនុស្សជាតិរស់នៅក្នុងភាពជាឈ្លើយនោះទេ ។ ទោះបីយ៉ាងណាក៏ដោយ យើងឃើញក្មេងៗដែលជាប់បំណុល និងភាពជាឈ្លើយខាងរូបកាយតាមរយៈការបង្ខិតបង្ខំឲ្យទៅជា

ពេស្យាចារ ។ អ្នកជួញដូរផ្លូវភេទ ចាប់ក្មេងនៅភូមិផ្សេងៗនៅឯទីផ្សារ និងនៅតាមដងផ្លូវ ។ ការអនុវត្តន៍ភាពយុត្តិធម៌គឺតែងតែមានភាពយឺតយ៉ាវ ដូចជាប្រព័ន្ធតំណាងឲ្យជនក្រីក្រហាក់បីដូចជា មិនដែលឈោងចាប់ដើម្បី បំពេញនូវសេចក្តីត្រូវការឡើយ ។ ព្រះជាម្ចាស់បានប្រាប់យើងថា គឺមាន មេឆបោកជាអនុភាពមួយដែលកំពុងធ្វើការដើម្បីកំទេច និងបំផ្លាញជីវិត ។ វាបង្ហាញខ្លួនដូចជាពស់នៅក្នុងលោកុប្បត្តិ ដើម្បីល្បួង និងបំប្លែងឲ្យខុស ។ ក្នុងការដែលយើងតស៊ូប្រយុទ្ធជាមួយភាពក្រីក្រ និងការកេងប្រវញ្ចន៍ ហើយនាំព្រះវត្តមានរបស់ព្រះដ៏ពេញលេញទៅក្នុងភាពខូចខាតនៃលោក នេះ យើងជួបអនុភាពនៃវិញ្ញាណអាក្រក់ទាំងអស់នេះ ។ ដូចដែល យើងធ្វើការជាមួយអ្នកដទៃទៀតនៅក្នុងសហគ្រាស នេះយើងត្រូវតែប្រើ អាវុធរបស់ព្រះដែលផ្តល់មកឲ្យយើង ដោយព្រោះ កំលាំង និងទឹកចិត្តតែ មួយគត់របស់យើងមិនគ្រប់គ្រាន់ទេ ។

ប្រវត្តិសាស្ត្រផ្តល់មកនូវគំរូនៃរាស្ត្ររបស់ព្រះ ដែលនាំការ បំផ្លាស់បំប្រែតាមរយៈការខិតខំប្រឹងប្រែងស្វែងរកនូវទស្សនៈផ្សេង ។ ពួកហោរាត្រូវបានជំរុញដោយសកម្មភាពនៃអំណាចគ្រប់គ្រង ។ អ្នកដឹក នាំត្រាស់ហៅឲ្យទទួលខុសត្រូវសំរាប់សេចក្តីស្មោះត្រង់ និងការយកចិត្ត ទុកដាក់ចំពោះជនក្រីក្រ ។ ជ័យជំនះនយោបាយមិនត្រូវបានគេទទួល ស្គាល់ទេ ប្រសិនបើអ្នកដែលងាយរងគ្រោះគ្មានឱកាសបញ្ចេញសំលេង ការពារផលប្រយោជន៍របស់ខ្លួន ។ នៅពេលដែលអ្នកក្រីក្រគ្មាននរណា យកចិត្តទុកដាក់ និងគ្មានច្បាប់ ឬប្រើច្បាប់ខុស ព្រះជាម្ចាស់ពិតជាបាន ត្រាស់ហៅយ៉ាងច្បាស់លាស់តាមរយៈហោរាផ្សេងៗ ឲ្យស្តារឡើងវិញនូវ សេចក្តីយុត្តិធម៌ ។ រឿងរបស់យ៉ូណាស គឺជាគំរូមួយអំពី ហោរាដែលមាន ការស្ទាក់ស្ទើរ នៅពេលដែលព្រះជាម្ចាស់ឲ្យនាំនូវព្រះបន្ទូលនៃការប្រែចិត្ត ទៅប្រាប់ដល់ទីក្រុង នីនីវេ ដើម្បីឲ្យពួកគេផ្លាស់ប្រែផ្លូវប្រព្រឹត្តរបស់គេ

បើមិនយ៉ាងដូច្នេះទេ ទីក្រុងនោះនឹងត្រូវបំផ្លាញ ។ ពិតប្រាកដណាស់ កម្ពុជាត្រូវការមេធាវី ឬអ្នកតស៊ូមតិដែលដើរតាមប្រពៃណីរបស់ពួកហោរាដែលហ៊ានចេញមុខនិយាយ និងការពារផលប្រយោជន៍អ្នកដទៃ - នៅក្នុងករណីនេះ សំរាប់កុមារដែលត្រូវបានគេជញ្ជូនយកផលប្រយោជន៍ដើម្បីបំពេញសេចក្តីត្រេកត្រអាល និងភាពចំណេញ នៅពេលដែលទេសចរណ៍កាន់តែមានការរីកចំរើនឡើង ។

ការបញ្ចេញសំដីអាចមានប្រសិទ្ធភាព ប៉ុន្តែប្រសិនបើគ្មានគំរោងការដ៏មានប្រាជ្ញាអាចបណ្តាលឲ្យមានបញ្ហាកាន់តែខ្លាំងឡើង ។ យើងប្រហែលជាមិនចង់ផ្តោតខ្លាំងទៅលើសាររបស់យើង ប៉ុន្តែលើខ្លួនឯងវិញដែលជាអ្នកនាំសារដើម្បីទទួលនូវកិត្តិស័ព្ទ ការគោរព និងការសរសើរ ។ ព្រះយេស៊ូ ត្រូវអារក្សល្បួងឲ្យព្រះអង្គធ្វើការអស្ចារ្យនៅក្នុងវាលរហោស្ថាន ។ ទ្រង់មានព្រះបន្ទូលថា ឯងមិនត្រូវល្បងព្រះអម្ចាស់នៃឯងឡើយ ។ នៅក្នុងការថ្លឹងថ្លែងរវាងឱកាស និងការប្រថុយ គឺយើងត្រូវការការប្រឹក្សាល្អ និងការអធិស្ឋានល្អ ។

យើងមានកាតព្វកិច្ចអធិស្ឋានប្រឆាំងទៅនឹងការកេងប្រវញ្ចន៍ ។ ការអធិស្ឋានរួម គឺជាការហ្វឹកហាត់នៅក្នុងការធ្វើឲ្យកាលៈទេសៈល្អប្រសើរឡើងដោយជំនឿ - "អធិស្ឋាននៅក្នុងអាណាចក្រ" ។ ការផ្លាស់ប្រែមិនដែលកើតមានឡើងភ្លាមៗចំពោះភ្នែករបស់យើងនោះទេ ។ ការបញ្ចប់ទាសភាព ត្រូវចំណាយពេលជាច្រើនឆ្នាំ ទើបវាពិតជាអាចកើតមានឡើងបាន ។ ថ្មីៗនេះមានមនុស្សជាច្រើនថែមទៀតបានអធិស្ឋានឲ្យមានការបញ្ចប់ការប្រកាន់ពូជសាសន៍ និងសូមឲ្យមានយុត្តិធម៌កើតឡើងនៅប្រទេសអាហ្វ្រិកខាងត្បូង ។

មនុស្សជាច្រើនអាចសូមអង្វរឲ្យរដ្ឋាភិបាល ឬក្រុមអន្តរជាតិផ្សេងៗ ។ នេះជាសេចក្តីត្រូវការជាពិសេសនៅពេលដែលធ្វើការជំនួស

មុខឲ្យក្រីក្របំផុតក្នុងចំណោមអ្នកក្រីក្រ ដែលគ្មានសំលេងផ្ទាល់ខ្លួនរបស់ពួកគេ ។ គ្រីស្តបរិស័ទត្រូវតែរួមចំណែកនៅក្នុងដំណើរការនេះ ។ អស់អ្នកដែលកាន់ខ្ជាប់តាមគតិលោករបស់គ្រីស្តបរិស័ទ ត្រូវតែជំរុញប្រឆាំងទៅនឹងការជិះជាន់ និងភាពអយុត្តិធម៌ ទាំងខាងវិញ្ញាណនយោបាយ និងក៏រិតនៃសង្គម ។

គ្រីស្តបរិស័ទជឿថា ព្រះជាម្ចាស់បង្កើតមនុស្សទាំងអស់នៅក្នុងរូបអង្គទ្រង់ ។ គ្រប់គ្នាបានទទួលភាពថ្លៃថ្នូរ និងឱកាសឲ្យស្គាល់ព្រះ ។ បាបគឺជារនាំងកាត់ផ្តាច់ទំនាក់ទំនងនេះ ប៉ុន្តែការសុគតរបស់ព្រះយេស៊ូវ គឺជាស្ពានតភ្ជាប់ឡើងវិញ ដោយទ្រង់សព្វព្រះទ័យលះបង់អង្គទ្រង់ផ្ទាល់សំរាប់យើង ។ ក្នុងខណៈពេលដែលព្រះយេស៊ូវផ្តល់អំណោយនៃការផ្សះផ្សាដល់យើង គឺព្រះអង្គផ្តល់ឱកាសមួយថ្មី ដើម្បីឲ្យយើងអាចទំនាក់ទំនងជាមួយព្រះសាជាថ្មីបាន យើងត្រូវតែប្រឆាំងដាច់ខាតទៅចំពោះរាល់អំណាចដែលស្វែងរកការបំផ្លាញ និងបន្ទាបបន្ថោករបស់ដែលព្រះជាម្ចាស់បង្កើតមក ។ ទោះបីជាយើងតែងតែខ្សោយក៏ដោយ យើងត្រូវបានផ្តល់កម្លាំងតាមរយៈសេចក្តីស្រឡាញ់នៃព្រះជាម្ចាស់ ហើយដូចគ្នាដែរត្រូវអនុវត្តសីលធម៌ ជ្រើសរើស និងប្រឆាំងចំពោះការប្រព្រឹត្តិយ៉ាងអយុត្តិធម៌ដល់អ្នកដទៃ ។ តាមរយៈទំនាក់ទំនងរវាងយើងជាមួយព្រះធ្វើឲ្យភ្នែករបស់យើងនឹង មើលឃើញ ហើយត្រចៀករបស់យើងនឹងឮការទាំងអស់នេះកាន់តែច្បាស់ឡើង ។

យើងក៏មានព្រះបន្ទូលសន្យាមកពីព្រះផងដែរនូវអ្វីដែលយើងគួរបញ្ចេញសកម្មភាព ។ "បើសិនជាមានពីរ ឬបីនាក់ជួបជុំគ្នាដោយនូវព្រះនាមព្រះអង្គនោះ ទ្រង់នឹងគង់នៅទីនោះ" ។ "សូមនោះអ្នកនឹងបានស្វែងរកនោះនឹងឃើញ" ។ យើងត្រូវតែរក្សាព្រះបន្ទូលសន្យាទាំងអស់នេះទុកជាកម្មសិទ្ធរបស់យើង បន្លឺសំលេងយើងឡើងទៅព្រះជាម្ចាស់

នៅក្នុងសេចក្តីអធិស្ឋានរបស់យើង ហើយអនុវត្តយ៉ាងណាតាមការដែលយើងអាចទៅរួច ។ នៅពេលដែលយើងធ្វើយ៉ាងដូច្នេះបាននោះព្រះអង្គនឹងត្រាស់ហៅយើងឲ្យបញ្ចេញសកម្មភាពបន្ថែមទៀត ។ ខ្ញុំសូមលើកទឹកចិត្តដល់បងប្អូនគ្រប់គ្នា ឲ្យស្តាប់សំលេងរបស់ព្រះនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ។ យើងប្រហែលជាត្រូវព្រះអង្គត្រាស់ហៅមកឲ្យទទួលការដឹកនាំ មិនមែនមកឲ្យដឹកនាំគេទេ ឲ្យមកផ្លាស់ប្រែ មិនមែនឲ្យមកត្រួតត្រាទេ ។ នេះគឺជាការត្រាស់ហៅរបស់ ពេត្រុស - ដែលគាត់អនុញ្ញាតឲ្យព្រះជាម្ចាស់ដឹកនាំខ្លួនគាត់ សូម្បីទៅកន្លែងដែលគាត់មិនចង់ទៅក៏ដោយ ។ អធិស្ឋានជាមួយអ្នកដទៃក្នុងភាពបន្ទាបខ្លួន និងស្វែងរកព្រះគុណនៃព្រះក្នុងហេតុការណ៍ដែលស្រែករកការធ្វើអន្តរាគមន៍ គឺជាការដែលគ្រីស្តបរិស័ទអាចធ្វើបានតាមរយៈទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះដែលបង្កើតខ្លួនមក ។ ក្មេងដែលត្រូវបានប្រើប្រាស់ដោយអ្នកទេសចរណ៍ដូចជារបស់លក់ដូរសំរាប់ផលប្រយោជន៍ និងភាពត្រេកត្រអាលរបស់ខ្លួន គឺជាហេតុផលមួយដែលយើងគួរគិតពិចារណា ។

## ទេសចរណ៍

ប្រទេសកម្ពុជាអូសទាញទេសចរណ៍ ២៧០០០០នាក់នៅក្នុងឆ្នាំ ១៩៩៩ ការទាយទុកជាមុនថាចំនួននឹងកើនឡើង ៣ដងនៅរយៈពេល៥ឆ្នាំខាងមុខ ។ ប្រទេសកម្ពុជាមានមោទនភាពខ្លាំងណាស់ក្នុងការចែកចាយភ្ញៀវនូវ កេរ្តិ៍មរតក និងវត្ថុល្បីល្បាញក្នុងលោកគឺអង្គរវត្ត ។ ប្រវត្តិសាស្ត្រថ្មីៗនេះ ក៏ផ្តល់ការចាប់អារម្មណ៍យ៉ាងខ្លាំងផងដែរដល់ភ្ញៀវទេសចរណ៍ ដើម្បីឲ្យពួកគេឃើញទឹកដីនេះដែលបាន (ចាប់ផ្តើមដោយដៃទទេ) ប្រែក្លាយពីស្រមោលនៃឆ្នាំសូន្យ ។ វាគឺជា ប្រទេសថ្មីមុខគេរួមជាមួយភាព

រំភើប និងភាពអាថ៌កំបាំងជាងប្រទេសជិតខាងនានា ដែលគេធ្លាប់មានអ្នកទេសចរណ៍ជាច្រើនទសវត្សមកហើយ ។

ទេសចរណ៍មានការងាយស្រួលទាក់ទងដល់ក្មេងដែលងាយរងគ្រោះតាមរយៈអំណាច និងសេដ្ឋកិច្ចជាមូលដ្ឋានទៅដល់ "វិស្សមកាលនៅលោកទីបីដ៏ថោក ដែលមានពន្លឺសូរិយា រលកសមុទ្រ និងសេពកាម" ។ នៅផ្នែកខាងក្រៅនៃប្រទេសកម្ពុជា មានការផ្សព្វផ្សាយតាមរយៈពាក្យដែលចេញពីមាត់ ការសន្ទនានៅក្នុងបន្ទប់អ៊ិនធឺណិត និងពេលខ្លះមានការបោះពុម្ពផ្សាយ ។ ប្រទេសថៃ និងប្រទេសហ្វីលីពីន សង្ឃឹមចង់បំបាត់នូវកេរ្តិ៍ឈ្មោះ ដែលល្បីរន្ទឺថាជាទីដៅនៃទេសចរណ៍ផ្លូវភេទ ពួកគេបានអនុវត្តច្បាប់ដើម្បីការពារកុមារ ។ ក្នុងខណៈពេលដែលប្រទេសទាំងនេះបង្កើននូវភាពតានតឹង ការចាប់អារម្មណ៍ត្រូវតែវិលរកកន្លែងផ្សេងវិញ ។ អ្នកទេសចរណ៍ផ្លូវភេទបានមានការទាក់ទាញដោយលក្ខខណ្ឌស្ថិតស្ថេរ ដែលមានការផ្សព្វផ្សាយតំលៃថោកនៃពេស្យាចារ ឱកាសដ៏ទូលំទូលាយ និងទទួលនូវភាពឥតមានទោសពីការចោទប្រកាន់ ។ ការប្តឹងចោទប្រកាន់ថ្មីៗនេះ និងជនជាប់ពន្ធនាគារដែលជាគ្រូជនជាតិអង់គ្លេសមួយរូបនោះ បានបង្ហាញឲ្យឃើញថា ភាពគ្មានទោសគឺមិនប្រាកដឡើយ ។ ទោះបីយ៉ាងណាក៏ដោយ ឆ្នាំថ្មីៗនេះប្រទេសកម្ពុជាមានការរីកចំរើនចំពោះអំពើពេស្យាចារលើកុមារ និងធ្វើឲ្យគ្រោះថ្នាក់ដល់កេរ្តិ៍ឈ្មោះរបស់ខ្លួន ឆ្លុះស្រមោលបាំងជាសាធារណៈនូវការផ្សព្វផ្សាយពីកេរ្តិ៍មរតកប្រពៃណីនៃប្រទេសជាគោលការណ៍ដែលទាក់ទងគ្នានោះ ។

## ផលប៉ះពាល់នៃការបំពានផ្លូវភេទរបស់កុមារ

ការបំពានផ្លូវភេទអាចបំផ្លាញជីវិតក្មេងដូច ដែលបានបង្ហាញនៅក្នុងរឿងរបស់ក្មេងស្រីអាយុ ១៦ឆ្នាំម្នាក់ ។ អង្គការទស្សនៈពិភពលោកធ្វើការជួយនាងចាប់តាំងពីឆ្នាំ១៩៩៩-២០០០ ។

នៅក្នុងអាយុ១៣ឆ្នាំ សុខាយល់ព្រមលក់ខ្លួន ក្នុងតំលៃ$៦០០ ទៅជនបរទេសម្នាក់ ដើម្បីជួយឲ្យគ្រួសារនាងមានលុយបង់ថ្លៃថ្នាំពេទ្យក្នុងការព្យាបាលជម្ងឺ ។ បន្ទាប់ពីនោះមកនាងចូលធ្វើជាពេស្យាចារអស់រយៈពេល២ឆ្នាំទៀតរហូតដល់នាងឈឺ ។ នៅពេលដែលការនោះកើតឡើងភ្ញៀវនឹងមិនទទួលនាងទៀតទេ ហើយនាងត្រូវបានបោះចេញទៅខាងក្រៅលើចិញ្ចើមថ្នល់ ។ យើងធ្វើការជួយនាងអស់រយៈពេលមួយឆ្នាំ នៅពេលដែលនាងមានជម្ងឺអេដស៍ ។ សុខាស្លាប់ក្នុងអាយុ ១៦ឆ្នាំ ទម្ងន់ស្រាលជាង២០គីឡូក្រាម ហើយគ្មានវត្តមានគ្រួសារនាងឡើយ ។ នាងផ្តល់នូវការប៉ះពាល់ចិត្តដល់អ្នកដទៃ ដោយបន្សល់ទុកនៅសេចក្តីថ្លៃថ្នូររបស់នាងក្រោយពីនាងស្លាប់ទៅ ហើយតាមរយៈនាង ពួកជំនុំរបស់នាងចាប់ផ្តើមរួមចំណែកក្នុងការសួរសុខទុក្ខស្ត្រីនៅឯមន្ទីរពេទ្យរុស្ស៊ីដើម្បីនាំការជួយផ្គត់ផ្គង់និងដំណឹងល្អ ។

រឿងនេះបង្ហាញពីភាពខ្សោយរបស់ជនរងគ្រោះ ការល្មើសអំណាចដោយអ្នកប្រព្រឹត្តបទល្មើស ភាពទន់ទាប ការបំពានលើរូបកាយ និងភាពឯកោនៅក្នុងការរងទុក្ខ ។ អង្គការទស្សនៈពិភពលោកបានរួមសហការជាមួយគ្រូពេទ្យសំរាប់សិទ្ធិមនុស្សក្នុងឆ្នាំ ១៩៩៦ ដើម្បីសរសេររបាយការណ៍ស្តីអំពីផលប៉ះពាល់ខាងផ្លូវចិត្តនៃការកេងប្រវញ្ចន៍ផ្លូវភេទ ។

ការសិក្សានេះ បង្ហាញឲ្យឃើញពីផលប៉ះពាល់ដល់កុមារដូចតទៅ:

របួសផ្លូវចិត្ត: ការរបួសផ្លូវចិត្តខាងផ្លូវភេទ គឺជាការបំពានយ៉ាងខ្លាំងទៅលើចំណុចសំខាន់នៃរឿងផ្ទាល់ខ្លួន ។ នៅពេលដែលរាងកាយរបស់ខ្លួនក្លាយទៅជាការដាក់នៅត្រង់ចំណុចនៃការប្រព្រឹត្តិនៃអំពើឃោរឃៅ ។ សំរាប់នារីក្មេងៗដែលរស់នៅក្នុងផ្ទះបនការបំពានទៅលើផ្លូវភេទត្រូវបានកើតមានឡើងនៅក្នុងបន្ទប់ដ៏តូចដែលជាកន្លែងរស់នៅផ្ទាល់ខ្លួនរបស់គេ ។ ពួកគេគ្មានទីជំរកដែលមានសុវត្ថិភាពឡើយ ។

ភាពអាម៉ាស់: ការចាប់អារម្មណ៍ទៅលើចិត្តសាស្ត្រយ៉ាងខ្លាំងមួយភ្ជាប់ទៅនឹងលក្ខណៈទូទៅនៃផ្លូវភេទចំពោះការរបួសផ្លូវចិត្ត ។ ការធ្លាក់ចុះនៃតំលៃផ្ទាល់ខ្លួនពេលខ្លះស្ថិតនៅលើចំណុចដែលមើលឃើញករណីផ្សេងទៀតពីព្រោះខ្លួនឯងគ្មានតំលៃទៀតឡើយ ។

ការក្បត់ការទុកចិត្ត: ប្រហែលជាចំនួនពាក់កណ្តាលនៃនារីក្មេងៗត្រូវបានលក់ទៅឲ្យផ្ទះបន ដោយមនុស្សដែលពួកគេស្គាល់ ។ អំពើក្បត់នេះអាចកើតមានរយៈពេលយូរ និងភាពទំនាក់ទំនង អភិវឌ្ឍយ៉ាងយឺតៗជាមួយក្មេងក្នុងការស្តារនូវអារម្មណ៍នេះឡើងវិញ ។ ពត៌មានគឺមានតំលៃខ្លាំងណាស់ និង ចែកចាយនូវអ្វីដែលវាអាចទទួល ។

ស្រទាប់នៃសេចក្តីពិត: រឿងផ្ទាល់ខ្លួនផ្សេងៗ ដែលមិនត្រឹមត្រូវបានទុកជារបៀបដើម្បីឲ្យក្មេងស្រីៗនោះយកមកប្រើ ។ ក្មេងស្រីខ្លះៗត្រូវបានប្រឌិតខ្លួនរបស់គេសាជាថ្មីជានិច្ច ដូចជាការផ្តល់ឲ្យនូវឈ្មោះថ្មី និងប្រវត្តិជារឿងរាល់សប្តាហ៍ដោយមេបនដែលមានការចង់គ្រប់គ្រង ពួកគេហើយការពារកុំឲ្យមានការស៊ើបអង្កេតរកឃើញនូវក្មេងស្រីៗ ដែលបាត់បង់ ។

ការបន្ទោសខ្លួនឯង: ក្មេងៗជាច្រើនបន្ទោសទៅលើកម្មផលរបស់ពួកគេ ដោយសរុបថា នេះគឺជាកម្មពៀរបស់គេដែលដឹកនាំពួកគេឲ្យទទួលនូវលទ្ធផលដូចបច្ចុប្បន្ននេះ ។

ការរំខានដល់ការអភិវឌ្ឍន៍សម្បជញ្ញៈ នារីក្មេងៗត្រូវបានបង្ខំចូលទៅក្នុងតួនាទីដែលញែកពួកគេពីសហគមន៍ ។ ពួកគេមិនអាចចូលរួមនៅក្នុងសកម្មភាពក្រៅផ្លូវការរបស់សង្គមបានទេ ដែលអាចរៀបចំពួកគេសំរាប់តួនាទីអនាគតទុកដូចជាអ្នកទទួលប្រាក់ចំណូល ជាប្រពន្ធ និងជាម្តាយដូចជាមនុស្សម្នាក់ដែរ ។

ការបែកចេញពីគ្រួសារៈ ទំនាក់ទំនងដែលសំខាន់ ទទួលនូវការរងទុក្ខ ។ មាននារីក្មេងជាច្រើនសោកសង្រេងដោយព្រោះមានការបាត់បង់អ្នកដែលអាចទំនាក់ទំនង ជាពិសេសជាមួយបងប្អូនបង្កើត ។

ការសោកសៅ និងភាពក្រៀមក្រំចិត្តៈ មានអារម្មណ៍អស់សង្ឃឹមកើតឡើងដោយសារបាត់បង់សេរីភាព ទំនាក់ទំនង និងភាពគ្មានទោស ។

ចិត្តភ័យខ្លាចៈ ការវាយដំ និងការដាក់ទារុណកម្មពីមេបនកើតឡើងជាទូទៅ ។ នារីក្មេងៗគឺពេញទៅដោយការភ័យខ្លាចចំពោះការឆ្លងជំងឺអេដស៍ ទោះបីយ៉ាងណាក៏ដោយ ពួកគេមិនអាចបដិសេធភ្ញៀវបានឡើយ ។

ភាពជាប់ជាឈ្លើយៈ ក្មេងស្រីៗមានការទ្រាំទ្រក្នុងភាពជាឈ្លើយជាច្រើនសប្តាហ៍ ជាច្រើនខែ និងពេលខ្លះរហូតដល់ឆ្នាំ ។ ពេលម្តងម្កាលពួកគេតទល់ជាមួយការបញ្ជារបស់មេបនចំពោះការបំរើភ្ញៀវ ។ លទ្ធផលគឺពួកនាងត្រូវគេចាក់សោឲ្យនៅក្នុងបន្ទប់អស់មួយសប្តាហ៍ ឬក៏ទទួលនូវការវាយដំរហូតដល់ពួកនាងយល់ព្រមធ្វើ ។ ពួកនាងមានការបាត់បង់អារម្មណ៍គ្រប់គ្រងទៅលើរឿងកម្មផលរបស់ពួកគេ ។

ភាពជាកុលធីតាៈ នៅក្នុងប្រពៃណីខ្មែរ រឿងនេះគឺជាកត្តាសំខាន់។ នារីក្មេងជាច្រើនមើលលើខ្លួនគេទុកដូចជាអ្នកដែលមានសមត្ថភាពក្នុងការជួយរំដោះគ្រួសាររបស់គេតាមរយៈធ្វើជាស្រីពេស្យា ។ នេះជាការឆ្លើយតបទៅចំពោះបរិបទ និងអត្ថន័យនៃការលះបង់ផ្ទាល់ខ្លួនរបស់គេ ។

ផលប៉ះពាល់ទាំងនេះ អាចមានប្រយោជន៍ដល់អស់អ្នកដែលជួយស្តារលទ្ធភាពឡើងវិញឲ្យជនរងគ្រោះទាំងនោះ ។

## កត្តានៃការចែកចាយ

អង្គការទស្សនៈពិភពលោកនៅក្រោមការទទួលចូលរួមសិក្សាជាមួយការិយាល័យអន្តរជាតិ និងអន្តោប្រវេសន៍នៅក្នុងឆ្នាំ ១៩៩៦ ដើម្បីឲ្យយល់ពីរបៀបនៃការជួញដូរផ្លូវភេទពីប្រទេសកម្ពុជាទៅប្រទេសថៃ ។ យើងរកឃើញកត្តាដូចតទៅ ដែលបង្កើននូវការប្រថុយគ្រោះថ្នាក់របស់ក្មេងស្រីដែលត្រូវបានលក់ ឬការជួញដូរផ្លូវភេទៈ

ភាពក្រីក្រ

ការខ្វះការអប់រំ

ការរួមចំណែកនៃសាច់ញាតិ

ការបោកបញ្ឆោតពីសំណាក់អ្នកជួញដូរផ្លូវភេទ (នៅក្នុងហេតុការណ៍ពេលដែលមនុស្សមិនបានដឹងអំពីរឿងអ្នកជួញដូរផ្លូវភេទ ឬមានការទុកចិត្តហួសពេក)

ការខ្វះការត្រួតពិនិត្យព្រំដែនឲ្យបានដិតដល់

ការខ្វះវិជ្ជាជីវៈផ្សេងៗ

សហគមន៍មិនជួយទប់ស្កាត់ដល់មុខរបរពេស្យាចារនៅក្នុងសហគមន៍ កត្តាទាំងនេះមិនមែនជាករណីលើកលែងទេចំពោះប្រទេសផ្សេងៗទៀត ។ អង្គការទស្សនៈពិភពលោកធ្វើការនៅក្នុងមធ្យោបាយជាច្រើនជាមួយអ្នកធ្វើការគ្រប់ប្រភេទដែលមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកុមារ ។

## តើអាចសំរេចបានយ៉ាងណាដើម្បីប្រឆាំងទៅនឹងប្រពន្ធ័រឿងរ៉ាវទាំងនេះ?

សេរីភាពចេញពីការជញ្ជក់យកផលប្រយោជន៍គឺអាចសំរេចឡើងបានតាមរយៈឧបករណ៍អន្តរជាតិដោយសន្ទត់សិទ្ធិរបស់កុមារ និងការប្រកាសជាទូទៅនៅក្នុងសិទ្ធិមនុស្ស ។ ប្រទេសដែលមានការគ្រប់គ្រងដោយច្បាប់ខ្លាំងក្លា មានវិធានការណ៍ជាមួយជនអន្តោពលជួញដូរផ្លូវភេទ ។ នេះមិនមែនរួមបញ្ចូលតែប្រព័ន្ធច្បាប់ ប៉ុន្តែទាំងផ្នែកពេទ្យ និងកម្មវិធីបំរើមនុស្ស ។ វេទិកាឆ្លើយឆ្លងជាសាធារណៈអាចជួយនូវការបញ្ចេញជាសាធារណៈនូវគំនិតដើម្បី ពង្រឹងក្រុមប៉ូលីស តុលាការ និង រដ្ឋាភិបាល ឲ្យទទួលខុសត្រូវ និងលើកទឹកចិត្តវេទិកាឆ្លើយឆ្លងនេះ ចំពោះសេចក្តីត្រូវការចង់ឲ្យមានការផ្លាស់ប្តូរ ។

អង្គការទស្សនៈពិភពលោកកម្ពុជា គឺជាអង្គការដែលផ្តោតចិត្តទុកដាក់ទៅលើកុមារមានព្រះគ្រីស្តជាគោល ជាជំនួយដល់កន្លែងផ្សេងៗ ទុកដូចជាសកម្មភាពសំខាន់ក្នុងការធ្វើការជាមួយអ្នកក្រ ស្វែងរក យុត្តិធម៌ និងផ្សព្វផ្សាយនូវការផ្លាស់ប្រែ ។ ប្រើសំលេងរបស់ខ្លួនដើម្បីនិយាយឡើង ដែលមានការទាក់ទងទៅនឹងរឿងដែលមានការប៉ះទង្គិចដល់កុមារភាព ហើយជួយជនក្រីក្រ និងសរសេរនៅវីមទំព័រនិយាយអំពីពួកគេ ។

## ការកេងប្រវញ្ចន៍ផ្លូវភេទកុមារ និងគម្រោងកម្មវិធីស្រាវជ្រាវទេសចរណ៍

ការកេងប្រវញ្ចន៍ផ្លូវភេទ ជាការល្មើសច្បាប់ច្បាស់ណាស់ទៅលើសិទ្ធិរបស់កុមារ ។ អង្គការទស្សនៈពិភពលោកទទួលគម្រោងកម្មវិធីដែលធ្វើការជាមួយកុមាររងគ្រោះ ។ ដូច្នេះអង្គការទស្សនៈពិភពលោកជាស្មរបន្ទាល់ទៅចំពោះលទ្ធផលខូចខាតដែលកើតឡើងចំពោះក្មេង -

ផ្នែករាងកាយ (ការឆ្លងកាមរោគ) ផ្នែកចិត្តសាស្ត្រ និងសង្គម (ចាត់ទុកជាអំពើទុយ៏សពីគ្រួសារ និងសង្គម) ។ គ្រប់ការទាំងអស់នេះនាំមកនូវភាពអត់ការងារធ្វើ ភាពឯកោ ជំងឺ និងរហូតដល់សេចក្ដីស្លាប់ ។

ចំពោះលទ្ធផលនេះ អង្គការទស្សនៈពិភពលោកបានចាប់ផ្ដើមធ្វើការស៊ើបអង្កេតនៃការតភ្ជាប់រវាងឧស្សាហកម្មទេសចរណ៍ និងការកេងប្រវ័ញ្ចន៍លើកុមារនៅក្នុងប្រទេសកម្ពុជា ។ ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងក្នុងការរួមចំណែកជាមួយសកលវិទ្យាល័យ អង្គការក្រៅរដ្ឋាភិបាល និងរបស់រដ្ឋាភិបាលក្រសួងជាច្រើន (រួមទាំងក្រសួងទេសចរណ៍) ។ ការស៊ើបអង្កេតនេះត្រូវបានគ្រោងឡើងតាមខ្សែបន្ទាត់ដូចតទៅ:

គោលដៅ:

ដើម្បីកាត់បន្ថយការកើតមានឡើងនូវការកេងប្រវ័ញ្ចន៍ខាងផ្លូវភេទទៅលើកុមារនៅក្នុងប្រទេសកម្ពុជា ហើយដើម្បីផ្សព្វផ្សាយយន្តការដើម្បីការពារកុមារចេញពីការកេងប្រវ័ញ្ចន៍ខាងផ្លូវភេទ តាមរយៈទេសចរណ៍ ។

វត្ថុបំណង:

- ដើម្បីបង្កើតឡើងឲ្យមានការប្រុងប្រយ័ត្ន ក្នុងចំណោមក្រសួងផ្សេងៗក្នុងរដ្ឋាភិបាលកម្ពុជា អំពីភាពទូទៅនៃបញ្ហា និងថាតើគួរដោះស្រាយដោយរបៀបណា ។
- ដើម្បីបង្កើតឡើងនូវការប្រុងប្រយ័ត្នក្នុងចំណោមក្មេងៗ និងគ្រួសាររបស់ពួកគេអំពីភាពជាទូទៅ និងការកើតឡើងនូវការអនុវត្តន៍ផ្សេងៗ ។

- ដើម្បីបើកសំដែងនូវសេចក្តីត្រូវការសំរាប់សហប្រតិបត្តិការ រវាងគ្រប់ផ្នែកទាំងអស់នៃរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិល ដើម្បីធ្វើការឆ្ពោះទៅរកការបញ្ចប់នៃការអនុវត្តន៍ទាំងនោះ ។

សកម្មភាព:

- <u>គំរោងស្រាវជ្រាវ</u> រៀបចំឡើងដោយអង្គការ ទស្សនៈពិភពលោកកម្ពុជា នៅក្នុងការធ្វើជាដៃគូជាមួយរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាសំរាប់កុមារ និងក្រសួងសង្គមកិច្ច ពលកម្ម និងហ្វឹកហ្វឺនវិជ្ជាជីវៈ ។
- <u>ការបោះពុម្ពរបាយការណ៍</u> "ការងារកុមារ តួនាទីនៃពួកមជ្ឈឹម វ័យៈ របាយការណ៍នៃការស្រាវជ្រាវទេចរណ៍ផ្លូវភេទទៅលើកុមារនៅក្នុងប្រទេសកម្ពុជា" ។ របាយការណ៍នេះត្រូវបានចែកចាយ នៅក្នុងចំណោមក្រសួងផ្សេងៗជាច្រើនរបស់រដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ដូចគ្នាដែរដល់ស្ថានទូតក្រសួងឧស្សាហកម្ម និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ។

អ្នកចូលរួម:

អ្នកសម្ភាសនៅក្នុងភ្នំពេញ សៀមរាប និង ក្រុងព្រះស៊ីហនុ:

| | |
|---|---|
| ៦៨នាក់ | កុមារ (អាយុ ១៥ឆ្នាំជាមធ្យម) |
| ២៦នាក់ | ម៉ូតូឌុប |
| ៣២នាក់ | បុគ្គលិករដ្ឋាភិបាលនៃក្រសួងទេសចរណ៍ |
| ១៨នាក់ | បុគ្គលិករដ្ឋភិបាលនៃក្រសួងកិច្ចការសង្គម កិច្ចការស្ត្រី និងប៉ុស្តិ៍នគរបាលផ្សេងៗតាមខេត្ត ។ |
| ៥នាក់ | បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល |

| | |
|---|---|
| ៣២នាក់ | កន្លែងនៃអ្នកទេសចរណ៍ ឧទាហរណ៍ បុគ្គលិកសណ្ឋាគារ និងផ្ទះសំណាក់ |
| ២០នាក់ | សាធារណជន |

## តើអ្នកណាខ្លះបានចូលរួមនៅក្នុងការរកចម្រូងប្រចម្លង ខាងផ្លូវភេទទៅលើកុមារ

ក្រសួងទេសចរណ៍បាននិយាយថា ៦៥%នៃភ្ញៀវទេសចរណ៍មកកម្ពុជានៅក្នុងឆ្នាំ ២០០០គឺជាបុរស។ ការស្រាវជ្រាវបានធ្វើឡើងជាមួយក្រសួងទេសចរណ៍ និងក្រុមប្រឹក្សាជាតិកម្ពុជាសំរាប់កុមារ នៅក្នុងកន្លែងទេសចរណ៍សំខាន់ៗ៣ ដែលសំដែងចេញដូចតទៅនូវពត៌មានចេញអំពីកុមារផ្ទាល់ ។

៨៨% នៃកុមារបានរួមចំណែកនៅក្នុងការផ្តល់របរផ្លូវភេទសំរាប់អ្នកទេសចរណ៍ ។ ពត៌មាននេះក៏បានចេញមកពីសមាជិក២០នាក់នៃសាធារណជនដែលរស់នៅកៀកទៅនឹងកន្លែងកំសាន្តសប្បាយ ។ ពួកគេប៉ាន់ស្មានថា ៤២% នៃក្មេងស្រីៗ ត្រូវបានយកចេញពីកន្លែងដោយ ភ្ញៀវ ៤៧% ទុកឲ្យនៅតែឯង ៩% បានទទួលយកទៅកន្លែងបន ។ គេបានប៉ាន់ស្មានថា ៦០% នៃកុមារដែលមានទំនាក់ទំនងជាមួយភ្ញៀវទេសចរណ៍គឺ ១៤ ដល់ ១៨ឆ្នាំ និង ៤០% គឺ១៨ ដល់ ២២ឆ្នាំ ។

ទីភ្នាក់ងារទេសចរណ៍២២ និងអ្នកប្រតិបត្តិការទេសចរណ៍នៅក្នុងកន្លែង៣ បានប៉ាន់ស្មានថា ក្រុមសំខាន់នៃអ្នកទេសចរណ៍ មានអស់អ្នកដែលមកលេងជាទេសចរណ៍ប្រពៃណី ៣២% ជាអ្នកជំនួញ ២៥% ជាអ្នកមកតាមផ្លូវការ ២០% និងជាទេសចរណ៍ផ្លូវភេទ ២២% ។

យោងទៅតាមអ្នកសម្ភាស ជនបរទេសដែលបានទាក់ទងកុមារមករួមរ័កខាងផ្លូវភេទមាន ៨៥% ជនជាតិចិន ២២% បារាំង ១៨% អាមេរិក ៨% អូស្ត្រាលី និង ៣៦% ជនអឺរ៉ុបមិនស្គាល់អត្តសញ្ញាណ ។

ក្នុងចំណោមមន្ត្រីក្រសួងទេសចរណ៍ទាំង ២៨រូបដែលបានសម្ភាស ៧៨%បាននិយាយថា ពួកគេឃើញកុមារដើរជាមួយបុរសបរទេសផ្សេងៗ ។ អ្នកសម្ភាសបង្ហាញពីក្រុមសំខាន់ៗនៃជនបរទេសថាកុមារដែលទៅជាមួយគេមានដូចតទៅៈ ១៨% អាមេរិក ១៨% ជប៉ុន ១៨% ចិន ៩% បារាំង និង ៣២% ពួកអឺរ៉ុបដែលមានស្បែកស ។

ឥទ្ធិពលថ្មីៗនៃការសិក្សាមានៈ

- ការបង្កើននូវការឆ្លើយតបរបស់រដ្ឋាភិបាលនៅក្នុងការហ្វឹកហ្វឺនច្បាប់ទំលាប់ និងការត្រួតពិនិត្យមគ្គុទេសក៍ទេសចរណ៍ ។
- បង្កើតនូវចាប់រដ្ឋាភិបាលសំរាប់មគ្គុទេសក៍អ្នកដឹកនាំទេសចរណ៍ និងការ ប្តេជ្ញាដើម្បីដាក់ក៏រិតដល់កម្មវិធីទេសចរណ៍ ។
- បង្កើនជាសាធារណៈនូវរឿងក្នុងស្រុក និងអន្តរជាតិ ឧទាហរណ៍ផ្សព្វផ្សាយតាមរលកធាតុអាកាសនៅក្នុងភាសាខ្មែរ និងCNN ។
- ផែនការសិក្ខាសាលាជាមួយរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងជំនួញនៅក្នុងតួនាទីនៃឧស្សាហកម្មទេសចរណ៍ នៅក្នុងការទប់ស្កាត់នូវជនដែលកំពុងកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ។
- ការប្តេជ្ញាមកពីអ្នកប្រតិបត្តិការទេសចរណ៍ខ្លះៗ ដើម្បីជាដៃគូជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងការផ្សព្វផ្សាយទេសចរណ៍ដែលផ្តល់សុវត្ថិភាពកុមារ ។
- ក្រសួងទេសចរណ៍ចែកចាយនូវការសិក្សានៅឯសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិ និងស្ថងការសង្គមសំរាប់អាស៊ី និងតំបន់

ប៉ាស៊ីហ្វិក ក្នុងសន្និសីទអន្តររដ្ឋាភិបាលក្នុងការទប់ស្កាត់នូវការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារដែលភ្ជាប់ទៅនឹងទេសចរណ៍ ។

- បន្តប្រតិបត្តិការជាមួយព្រះរាជាណាចក្រកម្ពុជា នៅក្នុងការប្រតិបត្តិសកម្មភាពរបស់គំរោង៥ឆ្នាំដើម្បីទប់ស្កាត់ការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ។
- ការស្រាវជ្រាវនេះ ត្រូវបានដាក់ប្រើដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងការបង្កើតនូវគំរោងយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ ។
- ស្ថានទូតអង់គ្លេស បានផ្ដល់ជំនួយដល់អង្គការទសន្សៈពិភពលោកដើម្បីធ្វើការជាមួយក្រសួងទេសចរណ៍សំរាប់២ឆ្នាំ ដើម្បីពង្រឹងនូវការហ្វឹកហ្វឺនដល់អ្នកដឹកនាំទេសចរណ៍ និងត្រួតពិនិត្យមើលអំពីបញ្ហានេះ ។

ការឆ្លើយតបមកពីរដ្ឋាភិបាលដូចដែលមានលទ្ធផលតាមរយៈការសិក្សានៅក្នុងខែកក្កដា ឆ្នាំ ២០០០ និងសិក្ខាសាលាជាបន្តបន្ទាប់បានធ្វើការរួមបញ្ចូលដូចតទៅៈ

- ប្រជុំធ្វើគំរោងសិក្ខាសាលាបន្ថែមទៀតជាមួយរដ្ឋាភិបាល. អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ និងជំនួញអំពីតួនាទីឧស្សាហកម្មទេសចរណ៍ នៅក្នុងការទប់ស្កាត់ចំពោះការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ។
- មានការប្ដេជ្ញាមកពីអ្នកប្រតិបត្តិការទេសចរណ៍ជាច្រើន ដើម្បីធ្វើជាដៃគូជាមួយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានាក្នុងការផ្សព្វផ្សាយដែលផ្ដល់សុវត្ថិភាពដល់កុមារ ។
- បង្កើននូវការភ្ជាប់ជាមួយឧស្សាហកម្ម និងអង្គការក្រៅរដ្ឋាភិបាលនានា ។

- ការថ្លែងពត៌មានរបស់ក្រសួងទេសចរណ៍ កាលពីខែកក្កដា ឆ្នាំ២០០០សិក្សានៅឯសន្និសីទអន្តររដ្ឋាភិបាលតាមតំបន់ នៅក្នុងការរារាំងដល់ការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ភ្ជាប់ទៅនឹងទេសចរណ៍ ។
- បញ្ចូលទៅក្នុងការសិក្សាស្រាវជ្រាវ និងគន្លឹះឲ្យមានសេចក្តីយល់ព្រមនៅក្នុងរាជរដ្ឋាភិបាលកម្ពុជារាយការណ៍ដល់សន្និសីទពិភពលោកទីពីរប្រឆាំងទៅនឹងការផ្សព្វផ្សាយពាណិជ្ជកម្ម អំពីការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារនៅក្រុង យូកូហាមា ក្នុងខែធ្នូ ឆ្នាំ២០០១។
- បន្តសហប្រតិបត្តិការរវាងក្រសួងទេសចរណ៍ និងអង្គការក្រៅរដ្ឋាភិបាលនានា ជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រតិបត្តិគំរោង ៥ឆ្នាំដើម្បីទប់ស្កាត់ការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ។
- ពិភាក្សាជាមួយសមាគមទេសចរណ៍ និងជំនួញផ្សេងៗ នៅក្នុងវិធានការណ៍តាមផ្លូវច្បាប់ វិធានការណ៍ផ្ទាល់ខ្លួនដើម្បីជួយការពារដល់សុវត្ថិភាពកុមារ ។
- នៅក្នុងការស្នើរបស់ក្រសួងទេសចរណ៍ ធនាគារអភិវឌ្ឍន៍អាស៊ីមានការបញ្ចូលទៅក្នុងការកសាងរដ្ឋាភិបាល និងកសាងសមត្ថភាពឧស្សាហកម្មទេសចរណ៍ ដើម្បីឆ្លើយតបទៅនឹងការធ្វើជំនួញទៅលើការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ទុកជាផ្នែកមួយ ដែលជាជំនួយដល់គំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៃរដ្ឋាភិបាលកម្ពុជា ។

## សរុបសេចក្តី

ការបំពានផ្លូវភេទរបស់កុមារ គឺមិនអាចទទួលបានឡើយ ។ វាតំរូវឲ្យមានសកម្មភាពក្នុងគ្រប់ទាំងកំរិតទាំងអស់ ។ ទេសចរណ៍មានការរីកចំរើន រួមបញ្ចូលគ្រប់ប្រទេសទាំងអស់ រួមបញ្ចូលទាំង ភ្ញៀវក្នុងស្រុក និងភ្ញៀវបរទេស ។ ស្តង់ដាឧស្សាហកម្មពិតប្រាកដជាត្រូវការខ្លាំងណាស់ ។ ការចោទប្រកាន់ត្រូវតែតម្រូវឲ្យមាន មិនថាអ្នកដែលយើងទប់ទល់នោះជាជនជាតិណាក៏ដោយ ។ រដ្ឋាភិបាលពិភពលោកជាមួយការជួយផ្គត់ផ្គង់ដោយអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិផ្សេងៗ មានការទទួលខុសត្រូវដើម្បីអះអាងថា កុមារត្រូវបានទទួលការការពារពីអំពើឃាតកម្មទាំងអស់នោះ ។ ប្រទេសអភិវឌ្ឍន៍ផ្សេងៗត្រូវការជំនួយតាមរយៈការចូលរួម ឧបតោភាគី និងពហុភាគីដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ទុកជាផ្នែកមួយនៃកំលាំងពួកគេដើម្បីកសាងសង្គមស៊ីវិល។ ជាងនោះទៅទៀត តំបន់ទេសចរណ៍ ត្រូវតែមានកាតព្វកិច្ចជៀសឲ្យឆ្ងាយចេញពីការអនុវត្តន៍ទាំងអស់នេះ ដែលអនុញ្ញាតឲ្យមានការកេងប្រវញ្ចន៍ផ្លូវភេទលើកុមារ ការផ្សព្វផ្សាយឲ្យមានការពារសុវត្ថិភាពកុមារ ។ ការចាប់ផ្តើមត្រូវតែមានការចូលរួមរបស់កុមារនៅក្នុងសហគមន៍ផ្សេងៗ ដើម្បីផ្សព្វផ្សាយអំពីសុវត្ថិភាពពិភពលោកសំរាប់កុមារ។ ប្រធានសហគមន៍នីមួយៗ ត្រូវតែមានការទុកចិត្ត ដើម្បីកុំឲ្យមានការ យល់ព្រមឲ្យមានការ ជួញដូរក្មេងស្រីទៀតឡើយ ...។

បរាជ័យក្នុងការអនុវត្តន៍មានន័យថា បរាជ័យក្នុងការជួយកុមារដូចជាសុខា ។ យើងបណ្តោយឲ្យពួកគេមានផ្លូវជ្រើសរើសតែបន្តិចបន្តួចរយៈពេលខ្លី និងជីវិតឈឺចាប់តែប៉ុណ្ណោះ ។ ត្រីស្តុបរិស័ទដឹងថាការនេះគឺមិនត្រឹមត្រូវទេ ហើយតាមរយៈព្រះគុណនៃព្រះ ជឿថាការទាំងអស់នឹងមានការរីកចំរើន ។ យើងត្រូវទទួលយកការជំរុញពីកាលៈទេសៈ

ទាំងអស់នេះ ហើយមិនធ្វើឲ្យខ្លួនយើងខុសប្លែកពីពួកគេឡើយ ។ ការបញ្ចេញសកម្មភាពគឺជាការកសាងឱកាសសំរាប់កុមារ ។ អស់អ្នកដែលមានឥទ្ធិពល អំណាចសេដ្ឋកិច្ច និងឯកសិទ្ធក្នុងការជ្រើសរើសពិតជាមានឥទ្ធិពលខ្លាំងណាស់ដល់ជីវិតកុមារ នៅក្នុងតំបន់ក្រីក្រជិតព្រំដែន និងទីជៅរបស់អ្នកទេសចរណ៍នានា ។ សកម្មភាពរបស់យើងឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់បំផុតនៅក្នុងតួនាទីនេះ ។